# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## ស្តីពីនិតិវិធីទូទាត់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងនេះធ្វើឡើងរវាង ក្រុមហ៊ុន ប្លាញតិច (ខេមបូឌា)ឯ.ក និងប្រតិភូបុគ្គលិកប្រចាំរោងចក្រ

ភាគីក្រុមហ៊ុនហៅថា **ភាគី "ក"** ភាគីប្រតិភូបុគ្គលិកនិងសហជីពមូលដ្ឋានហៅថា **ភាគី"ខ"**

**ភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងការចុះកិច្ចព្រមព្រៀងដែលមានលក្ខខណ្ឌដូចខាងក្រោមៈ**

**ប្រការ១: ក្រុមហ៊ុន ប្លាញតិច (ខេមបូឌា) ឯ.ក**និងអនុវត្តតាមសេចក្តីប្រកាសរបស់ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ០២០/២៣ ក.ប.ស.ណ.ខ.ល ស្តីពីការព្យួរកិច្ចសន្យាការងារ។

**កម្មករនិយោជិតត្រូវទទួលបានប្រាក់ឧបត្ថម្ភពីនិយោជក**

សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ត្រូវផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារដូចខាងក្រោមៈ

- ផ្តល់ប្រាក់ឧបត្ថម្ភចំនួន១៥ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងារមានរយៈពេល៧ថ្ងៃ ដល់១៤ថ្ងៃ។
- ផ្តល់ប្រាក់ឧបត្ថម្ភចំនួន៣០ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងារមានរយៈពេល១៥ថ្ងៃ ដល់១ខែ។

**ប្រការ២**: ភាគីទាំងពីរបានព្រមព្រៀងគ្នាបើកប្រាក់ឧបត្ថម្ភ ព្យួរកិច្ចសន្យាខាងលើរៀងរាល់ថ្ងៃទី១០នៃខែនីមួយៗ។

**ប្រការ៣**: ការអនុវត្ត ព្យួរកិច្ចសន្យាការងារលើកទី២ ចំនួន ២៨៥ នាក់ ស្រី២៥១ នាក់ រយៈពេល១៣ថ្ងៃ គិតចាប់ ពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាព និងអនុវត្តចាប់ពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣នេះតទៅ។

ប្លាញតិច, ថ្ងៃទី១២ ខែកញ្ញ ឆ្នាំ២០២៣

ប្រតិភូបុគ្គលិក

ហត្ថលេខា និងត្រា
នាយកក្រុមហ៊ុន

អ្នកស្រី យ៉ាង មុំធី

អ្នកស្រី អ៊ូ ស្រីនាង

លោក អឿន សំណាង

លោក ឈើន វិសាល

អ្នកស្រី យឿន មុំ

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ប្លាញតិច (ខេមបូឌា) ឯ.ក BLINGTEX (CAMBODIA) CO. LTD. KINGDOM OF CAMBODIA

Mr. Yang Ji You